# មតកសាសន៍ ៖ សារៈសំខាន់នៃយថាភូតភាព

មន្ទីរសារការីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៦ រក្សាសិទ្ធិគ្រប់យ៉ាង

**មតកសាសន៍** គឺជាលិខិតបណ្តាំដែលបុគ្គលម្នាក់ធ្វើឡើងដើម្បីសម្តែងឆន្ទៈចុងក្រោយ សំដៅធ្វើការការចាត់ចែងទ្រព្យនៅសល់របស់ខ្លួនជាអាទិ៍បន្ទាប់ពីមរណភាពរបស់ខ្លួន។

ទោះបីជាសមត្ថភាពខាងឆន្ទៈរបស់មតកជននៅពេលធ្វើមតកសាសន៍នោះ គឺជាល័ក្ខខ័ណ្ឌគ្រឹះតែមួយគត់ដែលមិនអាចខ្វះបានក៏ដោយ ក៏កង្វះល័ក្ខខ័ណ្ឌទម្រង់នៃមតកសាសន៍ នឹងដឹកនាំលិខិតបណ្តាំទៅរកមោឃភាពមិនខាន។

តាមច្បាប់កម្ពុជាសព្វថ្ងៃ មតកសាសន៍អាចធ្វើឡើងក្រោមបីទម្រង់គឺ៖ *មតកសាសន៍ដោយលិខិតយថាភូត* **មតកសាសន៍ដោយលិខិតឯកជន** និង*មតកសាសន៍ដោយលិខិតសម្ងាត់*។ ដោយសារនៅពេលអនុវត្តលិខិតបណ្តាំនេះ ម្ចាស់បណ្តាំបានស្លាប់ទៅហើយ ដែលនឹងមិនអាចមកអះអាងបញ្ជាក់អំពីខ្លឹមសារបណ្តាំរបស់ខ្លួនបានឡើយ ដូច្នេះ មតកសាសន៍ដោយលិខិតយថាភូតដើរតួជាបន្ទាល់ដ៏រឹងមាំដែលអាចទុកចិត្តនិងជឿជាក់បាន ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងតុលាការផង នាពេលកើតវិវាទ។



ដោយលោកស្រី **មិន្នស៊ុំ សូលីដា**
សារការីនៃមន្ទីរសារការីភ្នំពេញ

• • •

## មន្ទីរសារការីភ្នំពេញ

មន្ទីរសារការីភ្នំពេញត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៣៨ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១-១០-១៥ ដោយមានបេសកកម្មជាអាទិ៍៖

- ទទួលធ្វើកិច្ចសន្យា និងលិខិតគតិយុត្ត
- ផ្តល់យថាភូតភាពលើកិច្ចសន្យា ឬលិខិតគតិយុត្ត ឬឯកសារបកប្រែ
- ចេញសេចក្តីចម្លងយថាភូត
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃកិច្ចសន្យា និងលិខិតគតិយុត្ត
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ គ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃលិខិតគ្រប់ប្រភេទ
- បញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន
- បញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យា

*តើហេតុអ្វីបានជាទម្រង់យថាភូតនៃមតកសាសន៍មានសារប្រយោជន៍ខ្ពស់? តើអន្តរាគមន៍របស់សារការីនៅក្នុងការតាក់តែងមតកសាសន៍អាចជាជំនួយពិសេសអ្វីខ្លះ?*

មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើងដោយម្ចាស់បណ្តាំប្រាប់ផ្ទាល់មាត់នូវខ្លឹមសារ នៅចំពោះមុខសារការីដែលជាអ្នកកត់ត្រាខ្លឹមសារទាំងនោះជាលាយល័ក្ខណ៍អក្សរ។ មតកសាសន៍ ដែលធ្វើឡើងដោយសារការីដែលជាមន្ត្រីសាធារណៈ មានគុណប្រយោជន៍ពិសេសមួយចំនួនៈ

១-ឆន្ទៈរបស់ម្ចាស់បណ្តាំមិនអាចជំទាស់ប្រឆាំងបានឡើយនៅក្រោយមរណភាពរបស់ខ្លួនៈ សារការីមានតួនាទីក្នុងការពិនិត្យពិច័យសមត្ថភាពក្នុងការធ្វើបណ្តាំ និងឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ព្រមទាំងអនុលោមភាពនៃទម្រង់ និងខ្លឹមសារនៃមតកសាសន៍ទៅតាមច្បាប់ផងដែរ។ ក្រោយពីបានសរសេររួចរាល់នូវខ្លឹមសារបណ្តាំ សារការីត្រូវសូត្រសេចក្តីនោះឱ្យម្ចាស់បណ្តាំ និងសាក្សីពីររូបទៀតស្តាប់ និងទទួលស្គាល់ជាលាយល័ក្ខណ៍អក្សរលើខ្លឹមសារនោះ។ ដូច្នេះ ភាពច្បាស់លាស់ និងត្រឹមត្រូវនឹងអាចត្រូវបានធានានៅក្នុងល័ក្ខខ័ណ្ឌនេះ។

២-ការរក្សាទុកនូវមតកសាសន៍ ៖ សារការីដែលទទួលតាក់តែងមតកសាសន៍ មានកាតព្វកិច្ចរក្សាមតកសាសន៍នោះទុក សម្រាប់រយៈពេលយូរអង្វែង និងប្រកបដោយសុវត្ថិភាពខ្ពស់។ ដូច្នេះ ករណីនៃការក្លែងបន្លំ ឬការបាត់បង់នូវមតកសាសន៍ នឹងមិនអាចកើតមានឡើយ។

៣-ការអនុវត្តមតកសាសន៍ដោយលិខិតយថាភូតអាចធ្វើឡើងនៅក្រៅតុលាការៈ តាមច្បាប់កម្ពុជាបច្ចុប្បន្ន ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវមានការបញ្ជាក់លិខិតនោះ ដោយតុលាការជាមុនសិន នៅពេលចាប់ផ្តើមសន្តតិកម្ម។ ដោយឡែកមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការប៉ុណ្ណោះ ហើយបុគ្គលដែលបានបើកលិខិតមតកសាសន៍នេះ នៅក្រៅតុលាការ នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល។

*សូមកុំស្ទាក់ស្ទើរក្នុងការទាក់ទងមកសារការីរបស់លោកអ្នកដើម្បីធ្វើមតកសាសន៍!*

*រៀបចំឱ្យមានមតកសាសន៍សម្រាប់ខ្លួន គឺជាការបង្ការវិវាទដណ្តើមទ្រព្យក្នុងគ្រួសារផងដែរ!*

អគារកាណាឌីយ៉ា ជាន់ទី ១២ អគារលេខ៣១៥ ផ្លូវព្រះអង្គឌួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

Website: www.ppnp.com.kh

E-mail: info@ppnp.com.kh

Tel: 023 431 789

Fax: 023 431 678